# ព្រឹត្តិការណ៍ពាណិជ្ជកម្មហុងកុងផ្តល់ឱកាសដ៏មានអត្ថប្រយោជន៍សម្រាប់អាជីវកម្មកម្ពុជា

*រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ :* ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង (HKTDC) នឹងរៀបចំពិព័រណ៍អន្តរជាតិមួយចំនួននៅខែតុលា និងខែវិច្ឆិកានេះ ដែលមានសក្តានុពលសម្រាប់ក្រុមហ៊ុនកម្ពុជាដែលមានចំណាប់អារម្មណ៍ក្នុងការពង្រីកអាជីវកម្ម ឬពង្រឹងឋានៈរបស់ខ្លួននៅក្នុងតំបន់ ។ រហូតដល់ខែមីនាឆ្នាំក្រោយ ក្រុមហ៊ុននៅកម្ពុជានឹងទទួលបានកញ្ចប់ថវិកាឧបត្ថម្ភអ្នកទិញចំនួន ១០,៣ លានដុល្លារអាមេរិក (៨0 លានដុល្លារហុងកុង) ពីក្រុមប្រឹក្សា ។

លោក Johnny Wan ជាអ្នកចាត់ការពិព័រណ៍ជាន់ខ្ពស់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង កំពុងធ្វើទស្សនកិច្ចលើកដំបូងនៅប្រទេសកម្ពុជា ដើម្បីគូសបង្ហាញអំពីអត្ថប្រយោជន៍របស់ទីក្រុងហុងកុង និងសារៈសំខាន់នៃពិព័រណ៍ពាណិជ្ជកម្មរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង ។ លោកនឹងជួបជាមួយមន្ត្រីរាជរដ្ឋាភិបាល និងអង្គភាពអាជីវកម្មនានាដើម្បីពិភាក្សាអំពីបញ្ហាសហប្រតិបត្តិការអាជីវកម្ម សម្រាប់ពង្រីកសក្តានុពលពាណិជ្ជកម្ម រវាងប្រទេសកម្ពុជា និងទីក្រុងហុងកុង ។

លោក Wan បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មានថា "ទីក្រុងហុងកុងគឺជាវេទិកាពាណិជ្ជកម្មឧត្តុង្គឧត្តមមួយដែលមានបណ្តូរពាណិជ្ជកម្មសេរី ហេដ្ឋារចនាសម្ព័ន្ធលំដាប់ថ្នាក់ពិភពលោក និងលំហូរព័ត៌មានដោយសេរី ។ ដោយមានទីផ្សារកំពុងចាប់ផ្តើមមានសន្ទុះរីកចម្រើន ប្រទេសកម្ពុជាជាដៃគូពាណិជ្ជកម្មទី ៤២ របស់ទីក្រុងហុងកុងដែលមានទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីសរុបក្នុងតម្លៃចំនួន ៦១៧ លានដុល្លារអាមេរិក នៅឆ្នាំ២០០៨ ។ ដើម្បីទាញយកសក្តានុពលរបស់ប្រទេសកម្ពុជា យើងនឹងប្រើប្រាស់ពិព័រណ៍របស់យើង ដើម្បីជំរុញអោយមានពាណិជ្ជកម្មកាន់តែខ្លាំងក្លាថែមទៀតនៅក្នុងទីផ្សារនេះ" ។

ចម្ងាយជិតពីទីក្រុងហុងកុងទៅចិនដីគោក បង្ហាញនូវឱកាសអាជីវកម្មប្រកបដោយអត្ថប្រយោជន៍សម្រាប់ក្រុមហ៊ុនកម្ពុជា ។ "ពាណិជ្ជកម្មក្រៅប្រទេសសរុបរបស់ប្រទេសចិនបានកើនឡើងដល់ ១៧,៨% ស្មើនឹង ២.៥៦១.000 លានដុល្លារអាមេរិក នៅឆ្នាំ២០០៨។ ដូច្នេះ ពិព័រណ៍ពាណិជ្ជកម្មរបស់យើងគឺជាចំណុចចាប់ផ្តើមដ៏ល្អឥតខ្ចោះមួយសម្រាប់ក្រុមហ៊ុនកម្ពុជា ដើម្បីបង្កើត និងជំរុញពាណិជ្ជកម្មនៅចិនដីគោក ។

របាយការណ៍វិនិយោគពិភពលោករបស់អង្គការសហប្រជាជាតិក៏បានបង្ហាញផងដែរថា វិនិយោគផ្ទាល់ទៅបរទេសរបស់ប្រទេសកម្ពុជា មានទឹកប្រាក់ចំនួន ៣00 លានដុល្លារអាមេរិក រហូតមកដល់ឆ្នាំ២០០៨ ។ ទីក្រុងហុងកុងមិនគ្រាន់តែជាច្រកចូលទៅចិនដីគោកប៉ុណ្ណោះទេ ភាពប្រកួតប្រជែងខាងភូមិសាស្ត្រ សេដ្ឋកិច្ច នយោបាយ និងសង្គម ធ្វើអោយទីក្រុងហុងកុងក្លាយជាទិសដៅពាណិជ្ជកម្ម និងវិនិយោគល្អបំផុតសម្រាប់ក្រុមហ៊ុនកម្ពុជា ។
លោក Wan បានមានប្រសាសន៍ថា "ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុងនឹងរៀបចំពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិសំខាន់ៗជាច្រើននៅក្នុងខែតុលា ក្នុងនោះ ពិព័រណ៍ចំនួនពីរគឺជាពិព័រណ៍ធំបំផុតនៅទ្វីបអាស៊ី ។ ពិព័រណ៍ធំបំផុតសម្រាប់ព្រឹត្តិការណ៍ខែតុលា គឺពិព័រណ៍គ្រឿងអេឡិចត្រូនិកហុងកុងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង (វគ្គសរទរដូវ) និងពិព័រណ៍គ្រឿងភ្លើងអន្តរជាតិហុងកុងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង (វគ្គសរទរដូវ) ។ ពិព័រណ៍ពាណិជ្ជកម្មឯកទេសបីផ្សេងទៀតក្នុងពេលតែមួយនៅពិព័រណ៍អាស៊ី-ពិភពលោក (AsiaWorld-Expo) នាចុងខែតុលានេះ គឺមានពិព័រណ៍ប្រភពកីឡាអាស៊ី (Sports Source Asia) ពិព័រណ៍បរិស្ថានអាស៊ី (Eco Expo Asia) និងពិព័រណ៍

សម្ភារៈ និងបរិក្ខារសំណង់ និងតុបតែងលម្អអន្តរជាតិហុងកុង (Hong Kong International Building and Decoration Materials and Hardware Fair) ។ លោក Wan ក៏បានគូសបង្ហាញផងដែរថាពិព័រណ៍សុរា និងគ្រឿងស្រវឹងអន្តរជាតិហុងកុង (Hong Kong International Wine & Spirits Fair) នឹងត្រូវរៀបចំឡើងពីរដងជាលើកដំបូង ។

នៅពេលថ្លែងទៅកាន់ក្រុមអ្នកសារព័ត៌មាន លោក Wan ក៏បានប្រកាសអំពីកញ្ចប់ថវិកាឧបត្ថម្ភអ្នកទិញចំនួន ៨០ លានដុល្លារហុងកុង (១០,៣ លានដុល្លារអាមេរិក) សម្រាប់ប្រទេសកម្ពុជា ។ គំនិតផ្តួចផ្តើមនេះផ្តល់ជូននូវកញ្ចប់ឧបត្ថម្ភសម្រាប់សំបុត្រយន្តហោះ និងការស្នាក់នៅសណ្ឋាគារសម្រាប់អ្នកទិញអន្តរជាតិមកចូលរួមពិព័រណ៍ពាណិជ្ជកម្ម ដែលនឹងរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង រហូតដល់ខែមីនា ឆ្នាំ២០១០ ។ លោក Wan បានមានប្រសាសន៍ថា "អ្នកទិញកម្ពុជាដែលទៅទស្សនាពិព័រណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុងមានការកើនឡើងចំនួន ១៨% នៅឆ្នាំ២០០៨ បើធៀបទៅនឹងឆ្នាំមុន ។ កម្មវិធីនេះនឹងជំរុញអ្នកទិញអោយទៅចូលរួមទស្សនាពិព័រណ៍របស់យើងកាន់តែច្រើនថែមទៀត" ។

ដោយប្រារព្ធធ្វើនៅទំកណ្តាលទីក្រុង-មជ្ឈមណ្ឌលសមាជ និងពិព័រណ៍ហុងកុង (HKCEC) ពិព័រណ៍គ្រឿងអេឡិចត្រូនិកហុងកុងដ៏ធំបំផុតលើកទី ២៩ នៅអាស៊ី របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង (ថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែតុលា) គឺជាវេទិកាអាជីវកម្មសាកលសម្រាប់ភាគីឧស្សាហកម្មអេឡិចត្រូនិក ដោយមានផលិតផលអេឡិចត្រូនិកចម្រុះដាក់តាំងបង្ហាញ។ ឆ្នាំនេះ ផលិតផលថ្មីមានដូចជាកុំព្យូទ័រ និងគ្រឿងកុំព្យូទ័រ រូបភាពឌីជីថល ហ្គេមអេឡិចត្រូនិក និងគ្រឿងអេឡិចត្រូនិកថែទាំសុខភាព ។ "ពិព័រណ៍នឹងប្រារព្ធធ្វើឡើងក្នុងពេលដំណាលគ្នាជាមួយពិព័រណ៍អេឡិចត្រូនិកអាស៊ី (Electronic Asia) ហើយព្រឹត្តិការណ៍ទាំងពីរនេះនឹងអនុញ្ញាតអោយអ្នកទិញទទួលបានផលិតផល និងគ្រឿងបន្លាស់ប្រកបដោយគុណភាពនៅក្នុងពិភពអេឡិចត្រូនិក ។ ពិព័រណ៍អេឡិចត្រូនិកអាស៊ី ឆ្នាំ២០០៩ បង្ហាញអោយឃើញតំបន់ថ្មីមួយគឺពិភពថាមពលអគ្គិសនីបំលែងពីពន្លឺព្រះអាទិត្យ ដើម្បីបំពេញតាមតម្រូវការកំពុងតែកើនឡើងសម្រាប់ថាមពលផ្លាស់ថ្មីនេះ។

ព្រឹត្តិការណ៍ធំបំផុតមួយទៀតរបស់អាស៊ីនៅក្នុងមជ្ឈមណ្ឌលសមាជ និងពិព័រណ៍ហុងកុង គឺពិព័រណ៍គ្រឿងភ្លើងអន្តរជាតិហុងកុងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង ដែលនឹងរៀបចំឡើងពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែតុលា ។ ឆ្នាំនេះ តំបន់ភ្លើង LED និងតំបន់ភ្លើងបៃតងគឺត្រូវគេដាក់បញ្ចាំង ធ្វើអោយផលិតផលភ្លើងថ្មីបំផុតនេះអាចអោយអ្នកទិញងាយស្រួលរកបាន ។ "ទោះបីជាការនាំចេញគ្រឿងអេឡិចត្រូនិក និងគ្រឿងភ្លើងរបស់ហុងកុងទៅកាន់ប្រទេសកម្ពុជា មានទំហំតិចតួចក៏ដោយ ក៏អ្នកទិញកម្ពុជាអាចទទួលបានផលិតផលប្រកបដោយគុណភាពល្អកាន់តែច្រើនថែមទៀត និងស្វែងរកឱកាសអាជីវកម្ម តាមរយៈការទស្សនាពិព័ណ៌ទាំងពីរនេះ ដែលជាពិព័រណ៍ធំបំផុតរបស់អាស៊ីសម្រាប់ផលិតផលប្រភេទនេះ" ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុងរៀបចំពិព័រណ៍ពាណិជ្ជកម្មទ្រង់ទ្រាយធំ នៅក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មហុងកុងលំដាប់ខ្ពស់បំផុតរបស់អាស៊ី ដោយមានដាក់តាំងបង្ហាញម៉ូដសម្លៀកបំពាក់ពេញនិយម គ្រឿងអេឡិចត្រូនិក ល្បែងក្មេងលេង អំណោយ ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ គ្រឿងអលង្ការ និងផលិតផលផ្សេងៗទៀតជាច្រើន ។ ដើម្បីទទួលបានគុណប្រយោជន៍ពីពិព័រណ៍លំដាប់ខ្ពស់ថ្នាក់អន្តរជាតិរបស់យើង អ្នកទិញកម្ពុជាត្រូវបានលើកទឹកចិត្តអោយចូលរួមទស្សនាព្រឹត្តិការណ៍នេះ ។

លោក Wan បានសន្និដានថា "ពិព័រណ៍របស់យើងគឺជាកន្លែងដ៏ល្អបំផុត ដោយមានបង្ហាញតាំងពីឧបករណ៍ផ្សំរហូតដល់ផលិតផលសម្រេច តាំងពីម៉ូដែលបុរាណរហូតដល់ម៉ូដែលទំនើបៗ ។ ពិព័រណ៍នៅទីក្រុងហុងកុងផ្តល់ឱកាសដល់ក្រុមហ៊ុននៅប្រទេសកម្ពុជាអោយទទួលបានផលិតផលប្រកបដោយគុណភាព ចាប់យកភាពរីយឆ្លាតផ្នែកទីផ្សារ ចងសម្ព័ន្ធភាព និងទំនាក់ទំនងអាជីវកម្ម សម្រាប់ការពង្រីក និងការអភិវឌ្ឍនៅក្នុងទីផ្សារថ្មីៗទាំងនេះ" ។

ទំនាក់ទំនងព័ត៌មាន :
Jennifer Giang
ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង ការិយាល័យក្រុងហូជីមិញ
ទូរស័ព្ទ : ៨៤-(៨)-៣៨២៣-៥៨៨៣ ទូរសារ : ៨៤-(៨)៣៨២៣-៥៨៨៤
អ៊ីមែល : tn.giang@hktdc.org

Chloe Kiosk
ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង
ទូរស័ព្ទ : (៨៥២) ២២៤០ ៤៣៥៦ ទូរសារ : (៨៥២) ៣៥២១ ៣១៨៩
អ៊ីមែល : chloe.kiosk@hktdc.org